ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

# ឯកសារសិក្សាស្រាវជ្រាវ

# អំពី

# ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម


**រៀបចំដោយ** ៖លោក ហេង បូមករា
កញ្ញា សារុន ហៃលីដា

**កែសម្រួលដោយ** ៖លោកជំទាវ ជា សិរី
បណ្ឌិត ហ៊ាន ធារ៉ា


**ខែកញ្ញា ឆ្នាំ២០១៦**

# អារម្ភកថា

វិស័យកសិកម្មជាសសរទ្រូងមួយក្នុងចំណោមសសរទ្រូងសំខាន់ៗនៃសេដ្ឋកិច្ចប្រទេសកម្ពុជា និងត្រូវបានយកចិត្តទុកដាក់ជាអទិភាពពីសំណាក់រាជរដ្ឋាភិបាល ។ ចក្ខុវិស័យអភិវឌ្ឍន៍វិស័យកសិកម្មត្រូវបានចាត់ចូលជាធាតុមួយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលមានទិសដៅបង្កើនតម្លៃបន្ថែមនៃផលិតកម្មនិងការនាំចេញអង្ករដែលត្រូវបានចាត់ទុកជា "មាសស" របស់កម្ពុជា ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវទិសដៅប្រកបដោយសុទិដ្ឋិនិយម ដើម្បីជំរុញការនាំចេញអង្ករឲ្យបានកាន់តែច្រើនទៅប្រទេសជាដៃគូពាណិជ្ជកម្មរបស់ខ្លួន ។ ជាលទ្ធផល ផ្ទៃដីដាំដុះបង្កបង្កើនផលស្រូវរបស់ប្រជាកសិករព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធស្រោចស្រពត្រូវបានពង្រីកនិងកែលម្អជាបន្តបន្ទាប់ស្របពេលដែលមានការសម្រិតសម្រាំងពូជស្រូវ ការបង្កើនទំហំហិរញ្ញប្បទានវិស័យកសិកម្ម និងការពង្រីកទីផ្សារនាំចេញអង្ករ ផងដែរ ។ ទិន្នផលទទួលបានមានកំណើនជាលំដាប់ ដែលបានផ្តល់កាលានុវត្តភាពដល់កម្ពុជាក្នុងការបំពេញតម្រូវការក្នុងស្រុក ក៏ដូចជាការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងនាំចេញអង្ករ ជាមួយប្រទេសជិតខាងនិងក្នុងតំបន់ ។

ជាមួយនឹងវឌ្ឍនភាពទាំងនេះ អ្នកចូលរួមក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ-អង្ករនៅប្រឈមនឹងកត្តាមួយចំនួនដែលកំពុងរាំងស្ទះដល់ដំណើរការផលិតស្រូវ-អង្ករ ក៏ដូចជាក្នុងការឈានទៅសម្រេចគោលដៅនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ។ បញ្ហាដែលចោទឡើងបានចង្អុលបង្ហាញនូវដំណោះស្រាយជាចម្បង ដូចជាការពង្រឹងប្រព័ន្ធធារាសាស្ត្រដើម្បីឆ្លើយតបនឹងកត្តាអាកាសធាតុ ការលើកកម្ពស់ចំណេះដឹងនិងបច្ចេកទេសកសិកម្ម ការបន្តស្វែងរកទីផ្សារនាំចេញ និងការបង្កើនការផ្គត់ផ្គង់ធនធានហិរញ្ញវត្ថុ ជាដើម ។ ដូចនេះ ភាគីពាក់ព័ន្ធនៃវិស័យស្រូវ-អង្ករទាំងផ្នែកសាធារណៈនិងឯកជន ចាំបាច់ត្រូវយកចិត្តទុកដាក់និងបំពេញតួនាទីរបស់ខ្លួន ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ។ ផ្អែកលើស្មារតីនេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារដែលជាស្ថាប័នផ្តល់ហិរញ្ញប្បទាន បានរៀបចំនូវអត្ថបទស្រាវជ្រាវនេះឡើង ក្នុងគោលបំណងស្វែងយល់អំពីបញ្ហាប្រឈមរបស់អ្នកចូលរួមក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ-អង្ករ ដែលរួមមាន កសិករ និង ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ព្រមទាំងសកម្មភាពផ្តល់ហិរញ្ញប្បទានវិស័យកសិកម្មរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចំណាយពេលផ្តល់ព័ត៌មាននិងទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវ និង ជាពិសេសសហព័ន្ធស្រូវ-អង្ករកម្ពុជាដែលបានផ្តល់ការសហការសម្របសម្រួលក្នុងការចុះសិក្សាស្រាវជ្រាវនេះ ។ យើងខ្ញុំសង្ឃឹមថា លទ្ធផលដែលទទួលបាននេះ នឹងអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការពង្រីកចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវ សាធារណជនទូទៅ និងជាពិសេសបម្រើជាប្រយោជន៍ដល់ធនាគារជាតិនៃកម្ពុជា ព្រមទាំងក្រសួង-ស្ថាប័ននិងគ្រឹះស្ថានពាក់ព័ន្ធដទៃទៀត ក្នុងការរៀបចំគោលនយោបាយរបស់ខ្លួន ដើម្បីរួមចំណែកគាំទ្រដល់គោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្កររបស់ រាជរដ្ឋាភិបាលកម្ពុជា ។

# មាតិកា


អារម្ភកថា i

មាតិកា ii

បញ្ជីរូបភាព iii

១. សេចក្តីផ្តើម ១

២. ស្ថានភាពវិស័យស្រូវអង្ករនិងវិស័យហិរញ្ញវត្ថុ ៣

៣. ស្ថានភាពអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ និងរោងម៉ាស៊ីនកិនស្រូវ និង គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មស្រូវ-អង្ករ ៥

៣.១. ការអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ ៥

៣.២. ការអនុវត្តរបស់រោងម៉ាស៊ីនកិនស្រូវ ៧

៣.៣. ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៩

៤. ការសន្និដ្ឋាននិងផ្តល់យោបល់លើការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម ១២

ឯកសារយោង ១៤

# បញ្ជីរូបភាព


| | | |
|---|---|---|
| រូបភាព ១៖ | ស្ថានភាពទីតាំងប្រទេសកម្ពុជា និង កំណើនផលិតផលជាតិសរុប | ១ |
| រូបភាព ២៖ | ការនាំចេញអង្ករ និង ប្រភេទអង្ករនាំចេញ | ២ |
| រូបភាព ៣៖ | លទ្ធភាពនៃការបង្កបង្កើនផលស្រូវក្នុងមួយហិកតា (គិតជាតោន) | ៤ |
| រូបភាព ៤៖ | ឥណទានរបស់គ្រឹះស្ថានធនាគារ និង មីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច | ៤ |
| រូបភាព ៥៖ | បទពិសោធន៍នៃការដាំដំណាំស្រូវនិងទំហំដីរបស់ក្រុមគ្រួសារ សម្រាប់ការដាំដំណាំស្រូវ | ៥ |
| រូបភាព ៦៖ | កត្តាប្រឈមដែលជាឧបសគ្គក្នុងការដាំដំណាំស្រូវរបស់ប្រជាពលរដ្ឋ | ៦ |
| រូបភាព ៧៖ | រយៈពេលប្រតិបត្តិការរោងម៉ាស៊ីនកិនស្រូវ និងទំហំនៃការផលិត | ៧ |
| រូបភាព ៨៖ | កត្តាប្រឈមដែលជាឧបសគ្គសម្រាប់រោងម៉ាស៊ីនកិនស្រូវ | ៨ |
| រូបភាព ៩៖ | កត្តាប្រឈមដែលជាឧបសគ្គក្នុងការទទួលបានឥណទានពី គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៩ |
| រូបភាព ១០៖ | រយៈពេលនៃការផ្តល់កម្ចីដល់វិស័យកសិកម្ម | ១០ |
| រូបភាព ១១៖ | ប្រភេទអតិថិជននិងលក្ខខ័ណ្ឌក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម | ១០ |

# ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានស្ថានភាពដីរាបស្មើនៅកណ្តាល នឹងព័ទ្ធជុំវិញដោយភ្នំនិងខ្ពង់រាប ។ ក្នុងនោះ ផ្ទៃដីប្រមាណ ២៥.០៦៩គម² ជាដីទំនាប ៦៧.៦៦៨គម² ត្រូវបានហ៊ុមព័ទ្ធនៅជុំវិញបឹងទន្លេសាប ដែលជាប្រភពយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ដីដែលមានជីជាតិសម្រាប់ការប្រកបអាជីវកម្មកសិកម្ម និង ៦៨.០៦១គម² ជាដីខ្ពង់រាបនិងភ្នំ ហើយកំណើនសេដ្ឋកិច្ចមានការរីកចម្រើនគួរឲ្យកត់សម្គាល់ជាមួយអត្រាជាមធ្យមប្រមាណ ៧% ។

**រូបភាព ១៖ ស្ថានភាពទីតាំងប្រទេសកម្ពុជា និង កំណើនផលិតផលជាតិសរុប**







យោងតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០១៥ សេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរួមចំណែក ដោយវិស័យសំខាន់ចំនួន ៣ រួមមាន ៖ វិស័យកសិកម្ម (២៦,៦%) វិស័យឧស្សាហកម្ម (២៧,៧%) និង វិស័យសេវាកម្ម (៣៩,៨%) ហើយតាមរយៈលទ្ធផលស្ថិតិរបស់អង្គការម្ហូបអាហារនិងកសិកម្មបង្ហាញថាក្នុងឆ្នាំ២០១៣ វិស័យកសិកម្មបានផ្តល់ការងារដល់ប្រជាជនចំនួន ៦៤,៦% នៃកម្លាំងពលកម្មសរុប ។ ចំពោះវិស័យស្រូវអង្ករ លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ (Secretariat of One Window Service for Rice export Formality – SOWS-REF) បានបង្ហាញថាវិស័យស្រូវអង្ករកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងមុនឆ្នាំ២០១០ ដែលអាចឆ្លុះបញ្ចាំងតាមរយៈកំណើនបរិមាណនៃការនាំចេញអង្ករពីមួយឆ្នាំទៅមួយឆ្នាំ រួមមាន ៖ ឆ្នាំ២០០៩ (១២.៦១៣ តោន) ឆ្នាំ២០១០ (១០៥.២៦០ តោន) ឆ្នាំ២០១១ (២០១.៨៩៩ តោន) ឆ្នាំ២០១២ (២០២.៧១៧ តោន) ឆ្នាំ២០១៣ (៣៧៩.៨៥៦ តោន) ឆ្នាំ២០១៤ (៣៨៧.០៦១ តោន) និង ឆ្នាំ២០១៥ (៥៣៨.៣៩៦ តោន) ។

ទន្ទឹមនឹងការរីកចម្រើននេះវិស័យកសិកម្មគឺជាវិស័យមួយក្នុងចំណោមវិស័យអាទិភាពទាំង៤ ដែលត្រូវបានយកចិត្តទុកដាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ (២០១៣) ។ ក្នុងនោះ សកម្មភាពក្នុងការពង្រឹងការបន្តអភិវឌ្ឍនិងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម រួមមាន ៖ (១) ការបង្កើនតម្លៃបន្ថែមនៃការផលិតនិងការនាំចេញអង្ករ ពិសេសការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ (២) ការជំរុញការចញ្ចឹមសត្វនិងវារីវប្បកម្ម ដែលទីផ្សារត្រូវការ (៣) ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម និង (៤) ការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម ។

រូបភាព ២៖ ការនាំចេញអង្ករ និង ប្រភេទអង្ករនាំចេញ







ប្រភព៖ លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ (SOWS-REF)

ជាមួយគ្នាដែរ ក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដោយបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោល ក្នុងការសម្រេចឲ្យបាននូវការផលិតស្រូវឲ្យបានច្រើនជាង ៤ លានតោន និងជាអង្ករសម្រាប់នាំចេញជាផ្លូវការឲ្យបានយ៉ាងតិច ១ លានតោន និងការទទួលស្គាល់របស់អន្តរជាតិចំពោះអង្ករកម្ពុជា ។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (២០១៣) បានបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំស្រូវបានកើនឡើងយ៉ាងឆាប់រហ័សពី ២,៦ លានហិកតា និងមានបរិមាណផលស្រូវប្រមាណ ៧,១៧ លានតោន នៅឆ្នាំ២០០៨ ដល់ជាង ៣ លានហិកតា និងមានបរិមាណផលស្រូវប្រមាណ ៩,២៩ លានតោន នៅឆ្នាំ២០១២ ក្នុងនោះស្បៀងអាហារដែលនៅសល់ពីការហូបចុកនិងអាចនាំចេញបានមានចំនួន ៤,៧៣ លានតោន គិតជាស្រូវ និង ៣ លានតោនគិតជាអង្ករ ។ នេះជាកាលានុវត្តភាពថ្មីមួយ ដែលផ្តល់នូវសក្តានុពលដល់កម្ពុជាក្នុងការវិវត្តខ្លួនទៅជាប្រទេសនាំចេញអង្ករនាំមុខគេក្នុងពេលអនាគតដ៏ខ្លី ។ ប៉ុន្តែសមត្ថភាពក្នុងការនាំចេញនៅមានកម្រិតទាបនៅឡើយ និងទាមទារការយកចិត្តទុកដាក់បន្ថែមពីរាជរដ្ឋាភិបាល ក៏ដូចជាគ្រប់ភាគីពាក់ព័ន្ធ ។

ក្នុងឆ្នាំ២០១៥ គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានចំនួន ១.២២៩ លានដុល្លារអាមេរិក និង ១.០៦៥ លានដុល្លារអាមេរិក រៀងគ្នា ដល់វិស័យកសិកម្ម ដែលបរិមាណនេះស្មើនឹង ១០,២% និង ៣៥,២% នៃសំពៀតឥណទានសរុបរបស់គ្រឹះស្ថាន ។ ឥណទានដល់វិស័យកសិកម្មមានការកើនឡើងជាងឆ្នាំ២០១៤ ដែលឥណទានប្រមាណ ៩៥៣ លានដុល្លារអាមេរិក និង ៧៤៦ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ បើទោះជាការផ្តល់ឥណទានដល់វិស័យកសិកម្មមានការកើនឡើងក៏ដោយ មានមតិជាច្រើនបានលើកឡើងពីការខ្វះខាតនូវធនធានហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ក៏ដូចជាការសម្រេចបាននូវគោលនយោបាយនាំចេញអង្កររបស់រាជរដ្ឋាភិបាល ។ ផ្អែកលើការលើកឡើងខាងលើនេះ ធនាគារជាតិនៃកម្ពុជារៀបចំការសិក្សាស្រាវជ្រាវនេះឡើង ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពវិស័យកសិកម្ម និងតម្រូវការធនធានហិរញ្ញវត្ថុ លើការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា ។ លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះនឹងត្រូវបានប្រើប្រាស់ដើម្បីជាជំនួយដល់ធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំគោលនយោបាយសកម្មភាព ឲ្យកាន់តែមានប្រសិទ្ធភាព ។ ការសិក្សាស្រាវជ្រាវនេះ បានយកចិត្តទុកដាក់លើខេត្តចំនួន ៨ ដែលមានផលិតកម្មស្រូវ-អង្ករច្រើន ដែលរួមមាន ខេត្តបាត់ដំបង ព្រៃវែង កំពង់ចាម កណ្តាល កំពង់ធំ តាកែវ បន្ទាយមានជ័យ និង សៀមរាប

ដោយបានសាកសួរដល់ប្រជាកសិករចំនួន ៩៩ គ្រួសារ និង រោងម៉ាស៊ីនកិនស្រូវចំនួន ៥៣ រោងម៉ាស៊ីន ព្រមទាំងចុះសាកសួរដល់ទីស្នាក់ការកណ្តាលរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុចំនួន ៣០ គ្រឹះស្ថាន ។

អត្ថបទនៃការសិក្សាស្រាវជ្រាវនេះ បែងចែកជា ៤ផ្នែក រួមមាន៖ (១) សេចក្តីផ្តើម ដែលបង្ហាញពីគោលបំណង ទំហំ និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ (២) ស្ថានភាពវិស័យស្រូវអង្ករនិងវិស័យហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា និងការចូលរួមរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនៅក្នុងវិស័យនេះ (៣) ការអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និង គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មស្រូវ-អង្ករ និង (៤) ការសន្និដ្ឋាននិងផ្តល់យោបល់ ។

## ២. ស្ថានភាពវិស័យស្រូវអង្ករនិងវិស័យហិរញ្ញវត្ថុ

ប្រជាកសិករកម្ពុជាភាគច្រើន យកចិត្តទុកដាក់លើដំណាំស្រូវ ហើយផ្ទៃដីប្រមាណ ៧៥% ត្រូវបានប្រើប្រាស់សម្រាប់ការដាំស្រូវ ។ ផលិតកម្ម ដំណើរការនិងទីផ្សារស្រូវ បានផ្តល់ការងារដល់ប្រជាជនប្រមាណ ៣ លាននាក់ ឬ ២០% នៃប្រជាជនដែលមានវ័យគ្រប់គ្រាន់សម្រាប់បំពេញការងារ ។ ជាមួយគ្នាដែរ មួយផ្នែកធំនៃស្រូវដែលបានផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវបាននាំចេញទៅកាន់ប្រទេសថៃនិងវៀតណាមដើម្បីកិន រួចត្រូវបានចែកចាយសម្រាប់បំពេញតម្រូវការនៅក្នុងស្រុក ឬនាំចេញទៅបណ្តាប្រទេសផ្សេងទៀត ។ ការណ៍នេះ បង្កឲ្យបាត់បង់ឱកាសយ៉ាងច្រើនសម្រាប់រោងម៉ាស៊ីនកិនស្រូវនិងពាណិជ្ជករនៅកម្ពុជា ក្នុងការនាំចេញដោយផ្ទាល់ និងការបង្កើតការងារដល់ប្រជាជនក្នុងស្រុក ។ ទន្ទឹមនេះ ការយល់ដឹងរបស់កម្ពុជាអំពីបទដ្ឋាននិងតម្រូវការទីផ្សារអង្ករអន្តរជាតិនៅមានកម្រិត ដោយសារការទទួលព័ត៌មានមិនគ្រប់គ្រាន់ (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០១៥) ។

បើទោះជាយ៉ាងនេះក៏ដោយ ការបង្កើតបទដ្ឋានក្នុងការធានាលើគុណភាពសម្រាប់ "អង្ករស" និង "អង្ករក្រអូប" ចាប់តាំងពីឆ្នាំ២០១៣ កាន់តែជំរុញឱ្យមានការទទួលស្គាល់និងជំនឿទុកចិត្តជាអន្តរជាតិពីអ្នកទិញទូទាំងពិភពលោកលើគុណភាពអង្កររបស់កម្ពុជា ។ ការពង្រឹងបច្ចេកទេសកសិកម្មនិងដំណើរការកិន បានជំរុញទិន្នផលនិងប្រាក់ចំណូលដល់ឧស្សាហកម្មអង្ករកម្ពុជា ក៏ដូចជាកេរ្តិ៍ឈ្មោះក្នុងការផលិតអង្ករក្រអូប ។ ជាលទ្ធផលគួរជាទីមោទនៈ អង្ករកម្ពុជាបានទទួលចំណាត់ថ្នាក់ជាអង្ករឆ្ងាញ់បំផុតលើពិភពលោករយៈពេលបីឆ្នាំជាប់គ្នា នៅក្នុងសន្និសីទអង្ករពិភពលោកប្រចាំឆ្នាំដែលរៀបចំដោយ ក្រុមហ៊ុន The Rice Trader (TRT) ។ បើទៅជាយ៉ាងនេះក៏ដោយ អង្គការម្ហូបអាហារនិងកសិកម្ម (២០១៤) បានបង្ហាញថា លទ្ធភាពបង្កបង្កើនផលរបស់កម្ពុជានៅមានកម្រិតទាបធៀបនឹងប្រទេសជិតខាង ដែលជាមធ្យមការដាំដំណាំស្រូវទទួលផលបានត្រឹម ៣,៣ តោនក្នុងមួយហិកតា ប៉ុណ្ណោះ ខណៈដែលប្រទេសវៀតណាម និង ឥណ្ឌូនេស៊ីអាចផលិតបានដល់ ៦,២ តោន និង ៥,៧ តោន ក្នុង មួយហិកតា រៀងគ្នា ។

គោលនយោបាយស្តីពី "ការជម្រុញផលិតកម្មស្រូវអង្ករ និងការនាំចេញអង្ករ" ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១១ បានរៀបចំនូវផែនការសកម្មភាពសំដៅឆ្លើយតបនិងសម្រេចបាននូវទិសដៅដែលបានកំនត់តាមរយៈការយកចិត្តដាក់លើការបង្កើនផលិតភាព ជាពិសេស ប្រពលវប្បកម្មដំណាំស្រូវ និង ពិពិធភាវូបនីយកម្មកសិកម្ម និងការផ្តោតជាសំខាន់លើការបង្កើនសេវាកម្មនិងកិច្ចអន្តរាគមន៍នានា ដើម្បីជំរុញការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដីកត្តាអាកាសធាតុ ពិសេសគឺការកំណត់ប្រភេទពូជស្រូវសំខាន់ៗ ស្របតាមតំរូវការទីផ្សារ ជាដើម ។ ទន្ទឹមនេះ

ការសម្របសម្រួលនិងគាំទ្រវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ ស្របតាមតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ និងការប្រមូលផ្តុំផលិតកម្ម ក៏ជាយន្តការចាំបាច់ផងដែរ ដែលទាមទារឲ្យមានការគាំទ្រនិងយកចិត្តទុកដាក់យ៉ាងខ្លាំង ។

**រូបភាព ៣៖ លទ្ធភាពនៃការបង្កបង្កើនផលស្រូវក្នុងមួយហិកតា (គិតជាតោន)**




ប្រភព៖ អង្គការម្ហូបអាហារនិងកសិកម្ម (FAOSTAT)

វិស័យហិរញ្ញវត្ថុនៅកម្ពុជាគ្របដណ្តប់ដោយវិស័យធនាគារ ដែលក្នុងនោះទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុសរុបក្នុងឆ្នាំ២០១៥ បានកើនឡើងដល់ ២៣,៥ ពាន់លានដុល្លារអាមេរិក ។ ទន្ទឹមនេះ ឥណទានរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុសរុបបានកើនឡើងជាលំដាប់ដល់ ១៤,៧ ពាន់លានដុល្លារអាមេរិក ហើយឥណទាននេះត្រូវបានបែងចែកដល់វិស័យជាច្រើននៅក្នុងសេដ្ឋកិច្ច ។ យោងតាមទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៥ ឥណទានរបស់គ្រឹះស្ថានធនាគារភាគច្រើនបានបែងចែកដល់វិស័យពាណិជ្ជកម្មលក់ដុំ (១៧,០១%) ពាណិជ្ជកម្មលក់រាយ (១៥,៧៣%) កសិកម្មរុក្ខាប្រមាញ់និងនេសាទ (១០,១៩%) សេវាផ្សេងៗមិនមែនហិរញ្ញវត្ថុ (៨,៣៧%) កម្មន្តសាលកម្ម (៧,៦១%) និងការខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន (៧,១%) នៃសំពៀតឥណទានសរុប ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយកចិត្តទុកដាក់ផ្តល់ឥណទានដល់វិស័យកសិកម្ម (៣៥,២៤%) ក្រុមគ្រួសារ (២៦,២២%) ការជួញដូរនិងពាណិជ្ជកម្ម (១៩,៣៥%) សេវាកម្ម (១០,៦៦%) និងសំណង់និងដឹកជញ្ជូន (៧,១៧%) នៃសំពៀតឥណទានសរុប ។ នេះបង្ហាញថា ឥណទានសរុបប្រមាណ ២,៣ ពាន់លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់វិស័យកសិកម្ម ដោយគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

**រូបភាព ៤៖ ឥណទានរបស់គ្រឹះស្ថានធនាគារ និង មីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច**







ប្រភព៖ ធនាគារជាតិនៃកម្ពុជា (ឆ្នាំ២០១៥)

យោងតាមការសិក្សារបស់ធនាគារពិភពលោក ឆ្នាំ២០១៣ ប្រមាណជាពាក់កណ្តាលនៃកសិអាជីវកម្មកម្ពុជាបានប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ធនាគារពាណិជ្ជ ហើយកម្រិតនៃការប្រើប្រាស់សេវាធនាគារប្រែប្រួលទៅតាមទំហំនៃសហគ្រាស ។ ក្នុងនោះ ប្រមាណ ៨៥% នៃសហគ្រាសដែលប្រើប្រាស់សេវាធនាគារពាណិជ្ជ គឺជាសហគ្រាសខ្នាតធំ ហើយមានតែ ២២% ប៉ុណ្ណោះជាសហគ្រាសខ្នាតតូចបំផុត ។ ការសិក្សាក៏បង្ហាញផងដែរថា ភាគច្រើននៃអ្នកលក់អង្ករនិងអ្នកផ្គត់ផ្គង់វត្ថុធាតុដើម គឺជាសហគ្រាសខ្នាតតូចបំផុតនិងខ្នាតតូច ដែលក្នុងនោះមានអ្នកលក់អង្ករប្រមាណ ៨៦% និង អ្នកផ្គត់ផ្គង់វត្ថុធាតុដើមប្រមាណ ៨៥% ហើយជាសហគ្រាសខ្នាតធំ គឺមានតែអ្នកលក់អង្ករប្រមាណ ៣% និង អ្នកផ្គត់ផ្គង់វត្ថុធាតុដើមប្រមាណ ៥% ប៉ុណ្ណោះ ។

## ៣. ស្ថានភាពអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ និងរោងម៉ាស៊ីនកិនស្រូវ និងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មស្រូវ-អង្ករ

### ៣.១. ការអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ

ការដាំដំណាំស្រូវត្រូវបានអនុវត្តជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា ដូចមានភស្តុតាងបន្សល់ទុកពីសម័យមុនអង្គរ ។ ហើយសព្វថ្ងៃនេះ ប្រជាជនកម្ពុជាភាគច្រើនប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត ដូចជា ការនេសាទ ការដាំដំណាំ ការដាំស្រូវ និង ការចិញ្ចឹមសត្វជាដើម ។ យោងតាមទិន្នន័យដែលប្រមូលបានពីការសិក្សាស្រាវជ្រាវ កសិករដាំដំណាំស្រូវភាគច្រើនបានប្រកបមុខរបរនេះជាយូរមកហើយ ដែលភាគច្រើនមានបទពិសោធន៍ប្រមាណ ២០ឆ្នាំ និងមានមួយចំនួនតូចប៉ុណ្ណោះដែលតិចជាង ៥ឆ្នាំ និងភាគច្រើនរស់នៅក្នុងគ្រួសារជាមួយគ្នាដែលមានសមាជិកប្រមាណពី ៣ នាក់ ទៅ ១០ នាក់ ។ ការរស់នៅជាលក្ខណៈគ្រួសារដែលមានសមាជិកច្រើនបែបនេះនាំឲ្យពួកគាត់មានភាពងាយស្រួលក្នុងការជួយគ្នាបង្កបង្កើនផល ហើយជាមួយគ្នានេះ ការស្វែងរកលំនៅស្ថានថ្មីក៏មានការលំបាកផងដែរ ។ ក្នុងការដាំដំណាំស្រូវ កសិករប្រើប្រាស់ដីរបស់ខ្លួនដែលបន្សល់ទុកពីកេរ្តិ៍ដូនតា ដែលជាទូទៅមានដីប្រមាណពី ១ ហិកតា ទៅ ៥ ហិកតា ដោយអាចប្រមូលផលជាមធ្យមប្រមាណ ១ តោន ទៅ ៥ តោន ក្នុងមួយហិកតា ប៉ុន្តែ ដោយសារភាពអំណោយផលនៃតំបន់រស់នៅ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងការយល់ដឹងអំពីវិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទពូជស្រូវនិងការដាំដុះ មានកសិករប្រមាណ ៣៦% អាចមានលទ្ធភាពប្រមូលផលបានច្រើនជាង ៥តោន ។ ចំពោះទិន្នផលស្រូវដែលទទួលបានពីការដាំដុះ កសិកររក្សាទុកស្រូវមួយចំនួនតូចសម្រាប់ផ្គត់ផ្គង់តម្រូវការគ្រួសារ ហើយស្រូវប្រមាណ ៧៨% ត្រូវបានលក់ទៅឲ្យអ្នកប្រមូលទិញស្រូវ ។

**រូបភាព ៥៖ បទពិសោធន៍នៃការដាំដំណាំស្រូវ និង ទំហំដីរបស់ក្រុមគ្រួសារសម្រាប់ការដាំដំណាំស្រូវ**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

បើទោះជាយ៉ាងនេះក៏ដោយ កសិករភាគច្រើនបានបង្ហាញថា ទិន្នផលស្រូវដែលទទួលបានគឺមិនបានសម្រេចតាមការរំពឹងទុកទេ ដោយសារកត្តាមួយចំនួន ដូចជា (១) បញ្ហាអាកាសធាតុ (៦៤%) ដែលពេលខ្លះមានទឹកជំនន់ និងពេលខ្លះទៀតមានភាពរាំងស្ងួត (២) កម្លាំងពលកម្មមិនគ្រប់គ្រាន់ (១៦%) ដោយសារការធ្វើចំណាកស្រុករបស់សមាជិកក្នុងគ្រួសារទៅប្រទេសជិតខាងដែលអាចស្វែងរកប្រាក់ចំណូលដល់គ្រួសារ ច្រើនជាងការដាំដំណាំស្រូវ (៣) ការយល់ដឹងអំពីការដាំដំណាំស្រូវនៅមានកម្រិត (៨%) ដែលអនុវត្តទៅតាមបទពិសោធន៍និងចំណេះដឹងដែលទទួលបានពីឪពុក-ម្តាយ និងសមាជិកក្នុងក្រុមគ្រួសារ (៤) ការខ្វះខាតដើមទុនទិញវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ដំណើការដាំដុះ (៦%) និង (៥) ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ (៥%) ដែលមានការលំបាកក្នុងការធ្វើដំណើរទៅមក និងមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចដំណាំ ។ នេះបង្ហាញថា កត្តាប្រឈមចម្បងជាងគេដែលជាឧបសគ្គក្នុងការដាំដំណាំស្រូវរបស់ប្រជាពលរដ្ឋគឺការប្រែប្រួលអាកាសធាតុ ។

**រូបភាព ៦៖ កត្តាប្រឈមដែលជាឧបសគ្គក្នុងការដាំដំណាំស្រូវរបស់ប្រជាពលរដ្ឋ**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ចំពោះដើមទុន ប្រមាណ ៥៣% នៃកសិករ ប្រើប្រាស់ប្រភពទុនផ្ទាល់ខ្លួន ខណៈដែល ២៥% ប្រើប្រាស់ប្រាក់កម្ចីដែលទទួលបាន និង ២៣% ទៀតប្រើប្រាស់ទាំងទុនផ្ទាល់ខ្លួននិងប្រាក់កម្ចី ។ ក្នុងចំណោមកសិករដែលមិនបានខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានកសិករប្រមាណ ១៨% បានបង្ហាញនូវនិន្នាការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ កត្តាដែលជំរុញឲ្យកសិករ ភាគច្រើនជ្រើសរើសយកគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ គឺដោយសារអត្រាការប្រាក់អាចទទួលយកបាន និងទីស្នាក់ការរបស់គ្រឹះស្ថានមានភាពងាយស្រួលក្នុងការទំនាក់ទំនង ខណៈដែលកសិករផ្សេងទៀតបានបង្ហាញថា ការណ៍ដែលមិនមានបំណងខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ គឺដោយសារការមិនមានលទ្ធភាពសងបំណុល និងមិនមានការយល់ដឹងអំពីផលិតផលហិរញ្ញវត្ថុ ។ ក្រៅពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កសិករក៏បានខ្ចីប្រាក់ពីសាច់ញាតិ អ្នកឲ្យខ្ចីចងការ និង ការខ្ចីដីបណ្តាក់ ផងដែរ ។ កត្តាដែលជំរុញឲ្យពួកគាត់ជ្រើសរើសយកប្រភពទុនខាងលើ គឺដោយសារទីតាំងជិត និងមានភាពងាយស្រួលក្នុងការខ្ចីប្រាក់ ។

ក្នុងការទទួលបានកម្ចីពីប្រភពទុនខាងលើ កសិករភាគច្រើនត្រូវបង់កម្រៃអត្រាការប្រាក់ច្រើនជាង២២% ក្នុងមួយឆ្នាំ និងមានមួយចំនួនបង់ពី ១៨% ដល់ ២២% ក្នុងមួយឆ្នាំ ក្នុងនោះកម្ចីភាគច្រើនមានចំនួនពី ៤ លានរៀល

(១.០០០ ដុល្លារអាមេរិក) ដល់ ២០ លានរៀល (៥.០០០ដុល្លារអាមេរិក) និង តិចជាង ២លានរៀល (៥០០ ដុល្លារអាមេរិក) ដែលច្រើនជាងពាក់កណ្តាលនៃកសិករបង្ហាញថា បរិមាណនេះគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការរបស់ពួកគាត់ ។ ក្រៅពីនេះ បើទោះជាពួកគាត់តែងតែទទួលបានការយល់ព្រមផ្តល់កម្ចីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់ការខ្ចីប្រាក់ដើម្បីពង្រីកមុខរបរអាជីវកម្ម ពួកគាត់នៅតែប្រឈមនឹងបញ្ហាលំបាកមួយក្នុងការដាក់ពាក្យខ្ចីប្រាក់ ដូចជា វត្ថុបញ្ចាំ អត្រាការប្រាក់ និង អ្នកធានា ។ ជាទូទៅ តម្រូវការខ្ចីប្រាក់គឺនៅក្នុងអំឡុងពេលមុនភ្ជួររាស់ ដែលកសិករត្រូវការទុនសម្រាប់ទិញវត្ថុធាតុដើម ដើម្បីភ្ជួររាស់ និងប្រមូលផលកសិកម្ម ។

## ៣.២. ការអនុវត្តរបស់រោងម៉ាស៊ីនកិនស្រូវ

រោងម៉ាស៊ីនកិនស្រូវមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃការកែច្នៃ និងការនាំចេញអង្ករបស់កម្ពុជាតាមរយៈមុខងារជាអន្តរការីរវាងកសិករនិងអ្នកនាំចេញ ដូចជា ការប្រមូលស្រូវពីប្រជាកសិករ ជាដើម ។ ក្នុងនោះ ភាគច្រើននៃរោងម៉ាស៊ីនកិនស្រូវ មានប្រតិបត្តិការច្រើនជាង១០ឆ្នាំ ហើយមានតែរោងម៉ាស៊ីនកិនស្រូវមួយចំនួនប៉ុណ្ណោះ ដែលទើបតែចាប់ផ្តើមដំណើរការ ។ ចំពោះសមត្ថភាពនៃការផលិត រោងម៉ាស៊ីនកិនស្រូវប្រមាណ ៦២% អាចមានលទ្ធភាពកិនស្រូវក្នុងចន្លោះ ១.០០០ តោន ទៅ ១០.០០០ តោន និងប្រមាណ ៩% អាចកិនស្រូវបានច្រើនជាង ២០.០០០ តោន ក្នុងមួយឆ្នាំ ។ ទន្ទឹមនឹងលទ្ធផលដែលទទួលបាននេះ រោងម៉ាស៊ីនកិនស្រូវប្រមាណ ១៣% បានបង្ហាញនូវការពេញចិត្តរបស់ខ្លួន ដោយលទ្ធផលនេះអាចសម្រេចបានតាមសមត្ថភាពម៉ាស៊ីនរបស់ខ្លួន ប៉ុន្តែ ៧៧% នៃរោងម៉ាស៊ីនកិនស្រូវបានបង្ហាញថា លទ្ធផលដែលទទួលបាន គឺមិនអាចបំពេញតាមសមត្ថភាពដែលរំពឹងទុកឡើយ ដោយសារការខ្វះខាតធនធានហិរញ្ញវត្ថុ (៣៥%) មិនមានស្រូវគ្រប់គ្រាន់សម្រាប់កិន (១១%) ខ្វះខាតសម្ភារៈនិងជំនាញ (៨%) មិនមានជីនិងថ្នាំសំលាប់សត្វល្អិតគ្រប់គ្រាន់ (៧%) និង កត្តាផ្សេងៗ (៣៩%) ដូចជា កម្លាំងពលកម្មមិនគ្រប់គ្រាន់ មិនមានទីផ្សារលក់ អគ្គិសនីមានតម្លៃថ្លៃ និង ការប្រមូលទិញស្រូវរបស់ប្រទេសជិតខាង ជាដើម ។

**រូបភាព ៧៖ រយៈពេលប្រតិបត្តិការរោងម៉ាស៊ីនកិនស្រូវ និងទំហំនៃការផលិត**







ប្រភព៖ ទិន្នន័យស្រាវជ្រាវ

រូបភាព ៨៖ កត្តាប្រឈមដែលជាឧបសគ្គសម្រាប់រោងម៉ាស៊ីនកិនស្រូវ




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ក្នុងការប្រមូលទិញស្រូវ រោងម៉ាស៊ីនកិនស្រូវមិនអាចរំពឹងតែប្រភពស្រូវដែលមាននៅក្នុងខេត្តនោះទេ ត្រូវពឹងផងដែរពីខេត្តផ្សេងទៀត ដែលអាចជាកសិករ និង អ្នកប្រមូលស្រូវ ។ ក្នុងចំណោម រោងម៉ាស៊ីនកិនស្រូវដែលប្រឈមនឹងកង្វះខាតដើមទុន បានបង្ហាញថាក្រៅពីប្រាក់សន្សំផ្ទាល់ខ្លួននិងការខ្ចីពីសាច់ញាត្តិ ពួកគាត់ក៏មានបំណងខ្ចីប្រាក់បន្ថែមពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ជាពិសេស គ្រឹះស្ថានធនាគារ ដោយសារដំណើការនៃការខ្ចីប្រាក់មានភាពងាយស្រួល និងអត្រាការប្រាក់មានកម្រិតជាមធ្យមប្រមាណ ៨% ទៅ ១០% ក្នុងមួយឆ្នាំទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ បើទោះជាយ៉ាងនេះក៏ដោយ មានរោងម៉ាស៊ីនកិនស្រូវមួយចំនួនមិនបានបង្ហាញពីនិន្នាការខ្ចីប្រាក់ពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ ដោយយោងលើកត្តាមិនមានលទ្ធភាពសង ។

ចំពោះរោងម៉ាស៊ីនកិនស្រូវដែលបានទទួលឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ច្រើនជាងពាក់កណ្តាលនៃពួកគេ បានទទួលឥណទានពី ១០០.០០០ ដុល្លារអាមេរិក ទៅ ១.០០០.០០០ ដុល្លារអាមេរិក ហើយប្រមាណ ២២,៥% បានទទួលឥណទានលើសពី ១.០០០.០០០ ដុល្លារអាមេរិក ហើយភាគច្រើននៃសំណើកម្ចីឥណទានរបស់រោងម៉ាស៊ីនកិនស្រូវ តែងតែទទួលបានការអនុម័តយល់ព្រមពីគ្រឹះស្ថាន ។ បើទោះជារោងម៉ាស៊ីនកិនស្រូវទទួលបានកម្ចីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ដោយ រោងម៉ាស៊ីនកិនស្រូវប្រមាណ ៨៣% នៅតែបង្ហាញថាឥណទានដែលទទួលបាន គឺមិនគ្រប់គ្រាន់សម្រាប់ការទិញស្រូវនិងការពង្រីកអាជីវកម្មបន្ថែមទេ ។ ក្រៅពីនេះ កត្តាប្រឈមចម្បងសម្រាប់រោងម៉ាស៊ីនកិនស្រូវក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺវត្ថុបញ្ចាំ និងអត្រាការប្រាក់ ។

គួរកត់សម្គាល់ថា ក្នុងពេលថ្មីៗនេះមានរោងម៉ាស៊ីនកិនស្រូវមួយចំនួនត្រូវបានបិទទ្វារ ដែលការណ៍នេះអាចនឹងមានការរួមចំណែកដោយការប្រើប្រាស់ធនធានហិរញ្ញវត្ថុមិនសមស្រប ដូចជាការវិនិយោគលើការពង្រីកអាជីវកម្ម ធំជាងតម្រូវការដែលបង្កឲ្យមានការចំណាយខ្ពស់ តែផលចំណេញដែលទទួលបានមកវិញតិចជាងការចំណាយ ។ ប៉ុន្តែ រោងម៉ាស៊ីនកិនស្រូវមួយចំនួនបានបង្ហាញថា បើទោះជារោងម៉ាស៊ីនមានសាច់ប្រាក់គ្រប់គ្រាន់ក៏ដោយ ការថយចុះនៃការដាំដំណាំស្រូវរបស់ប្រជាកសិករ ជាកត្តាមួយបង្កឲ្យរោងម៉ាស៊ីនពិបាករកស្រូវមកកិន និងត្រូវចំណាយថ្លៃដើមខ្ពស់ក្នុងការផលិត ការថែរក្សា និងការដឹកជញ្ជូន ។

រូបភាព ៩៖ កត្តាប្រឈមដែលជាឧបសគ្គក្នុងការទទួលបានឥណទានពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

## ៣.៣. ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ច ប្រព័ន្ធធនាគារនៅកម្ពុជា បានអភិវឌ្ឍជាបន្តបន្ទាប់ទៅតាមការវិវត្តនៃទីផ្សារ ។ គិតត្រឹមចុងឆ្នាំ២០១៥ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន ៖ ធនាគារពាណិជ្ជ ៣៦ ធនាគារឯកទេស ១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៨ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៥០ ។ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា បានផ្តល់កម្ចីដល់គ្រប់វិស័យ ក្នុងនោះវិស័យកសិកម្មតែងតែទទួលបានឥណទានច្រើន បើធៀបទៅនឹងវិស័យដទៃទៀត ដោយរួមបញ្ចូលទាំងការដាំដុំណាំស្រូវ ការចិញ្ចឹមត្រី និង ការដាំបន្លែ ជាដើម ។ យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៥ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានសរុបចំនួន ១៤,៧ ពាន់លានដុល្លាអាមេរិក ហើយឥណទានប្រមាណ ១៥,៥% ត្រូវបានផ្តល់ ដល់វិស័យកសិកម្ម (គ្រឹះស្ថានធនាគារចំនួន ១,២ ពាន់លានដុល្លារអាមេរិក និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១,១ ពាន់លានដុល្លារអាមេរិក) ។ គ្រឹះស្ថានដែលយកចិត្តទុកដាក់ក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម រួមមាន ៖ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារអេសហេចប៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា ជាដើម ។ ធនាគារអេស៊ីលីដាបាននាំមុខគេក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ដែលឥណទានប្រមាណ ៥១៦ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់វិស័យនេះ ខណៈដែលធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់ឥណទានប្រមាណ ៦៤ លានដុល្លារអាមេរិក ។

ក្នុងចំណោមគ្រឹះស្ថានទាំងនេះមានគ្រឹះស្ថានធនាគារប្រមាណ ៤៣% បានផ្តល់ឥណទានដល់វិស័យកសិកម្មអស់រយៈពេលជាង១០ឆ្នាំ មកហើយ ហើយប្រមាណ ៣៦% នៅចន្លោះពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន (៩៣%) បានផ្តល់ឥណទានដល់វិស័យនេះច្រើនជាង ១០ឆ្នាំ ។ ទន្ទឹមនេះ ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់វិស័យកសិកម្មមានជាមធ្យមប្រមាណ ១០% និង ៣៥% នៃឥណទានសរុបរបស់ខ្លួន ។ ការណ៍នេះបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ។

**រូបភាព ១០៖ រយៈពេលនៃការផ្តល់កម្ចីដល់វិស័យកសិកម្ម**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានកំណត់អតិថិជនគោលដៅនៃវិស័យកសិកម្មរបស់ខ្លួនខុសៗគ្នា ។ ក្នុងនោះ ប្រមាណ ៧០% នៃឥណទានរបស់គ្រឹះស្ថានធនាគារ ផ្តល់ដល់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ ខណៈដែល ៥២% នៃឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់ដល់កសិករ ហើយមានតែឥណទាន ២២% ដែលផ្តល់ដល់រោងម៉ាស៊ីនកិនស្រូវ ។ ការណ៍នេះគឺដោយសាររោងម៉ាស៊ីនកិនស្រូវនិងអ្នកនាំចេញអង្ករ មានតម្រូវការឥណទានទំហំធំ ហើយកសិករភាគច្រើនមានតម្រូវការឥណទានទំហំតូច ។

**រូបភាព ១១៖ ប្រភេទអតិថិជននិងលក្ខខ័ណ្ឌក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ទន្ទឹមពេលដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានដល់គ្រប់វិស័យ ការផ្តល់ឥណទានដល់វិស័យកសិកម្មមិនត្រូវបានកំណត់ផ្សេងគ្នាទៅនឹងវិស័យដទៃឡើយ គឺត្រូវគោរពតាមលក្ខខ័ណ្ឌឥណទានដែលគ្រឹះស្ថានបានកំណត់ ដូចៗគ្នា ។ ទន្ទឹមនេះផងដែរ អតិថិជនត្រូវបំពេញលក្ខខ័ណ្ឌមួយចំនួនក្នុងការស្នើសុំឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដូចជាវត្ថុបញ្ចាំ លទ្ធភាពក្នុងការសងបំណុល ផែនការអាជីវកម្ម និងអ្នកធានាជាដើម ។ ក្នុងចំណោមលក្ខខ័ណ្ឌទាំងនេះគ្រឹះស្ថានធនាគារយកចិត្តទុកដាក់សំខាន់លើវត្ថុបញ្ចាំ និងផែនការអាជីវកម្មដែលការណ៍នេះអាចជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋនៅទីជនបទ ដែលមិនមានប្លង់ផ្ទះនិងប្លង់ដីត្រឹមត្រូវក៏ដូចជា ក្រុមហ៊ុនតូចៗដែលមិនមានការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងផែនការអាជីវកម្មច្បាស់លាស់ ។ ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិនិត្យមើលសំខាន់លើលទ្ធភាពក្នុងការសងបំណុលនិងវត្ថុបញ្ចាំ ហើយគ្រឹះស្ថានក៏ពិចារណា

អំពីអ្នកជានាផងដែរ ខណៈដែលផែនការអាជីវកម្មត្រូវបានយកចិត្តទុកដាក់តិចតួច ។ ក្នុងចំណោមឥណទានដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ជូនអតិថិជនដែលមានទ្រព្យបញ្ចាំ រួមមាន ៖ ប្លង់ដីនិងប្លង់អាគារ ៧៩% និង ចលនទ្រព្យផ្សេងៗ ៣១% ។ លើសពីនេះ គ្រឹះស្ថានបានបង្ហាញថា បើទោះជាអតិថិជនមិនមានទ្រព្យបញ្ចាំក៏ដោយ ប្រមាណ ២០% និង ៥៤% នៃអ្នកដាក់ពាក្យស្នើសុំ បានទទួលឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ខណៈដែលអតិថិជនប្រមាណ ៥៣% និង ២៧% ដែលដាក់ពាក្យស្នើសុំដោយមិនមានផែនការអាជីវកម្ម អាចទទួលបានឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

ចំពោះការប្រាក់ប្រចាំឆ្នាំ កម្ចីពីគ្រឹះស្ថានធនាគារមានអត្រាទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ជាទូទៅការប្រាក់អប្បបរមានៃកម្ចីពីគ្រឹះស្ថានធនាគារមានអត្រាចន្លោះពី ៦% ដល់ ៨% និង អត្រាអតិបរិមាចន្លោះពី ៩% ទៅ ១១% ខណៈដែលការប្រាក់អប្បបរមានៃកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអត្រាចន្លោះពី ១៨% ដល់ ២០% និង អត្រាអតិបរិមាភាគច្រើនធំជាង ២៣% ផងដែរ ។ ការផ្តល់ឥណទានចំពោះវិស័យកសិកម្ម ត្រូវបានគិតអត្រាប្រហាក់ប្រហែលគ្នានឹងការផ្តល់ឥណទានដល់វិស័យផ្សេងទៀតដែរ ហើយភាគច្រើននៃកម្ចីគឺមានរយៈពេលច្រើនជាង ៣ឆ្នាំ ជាពិសេសឥណទានរបស់គ្រឹះស្ថានធនាគារ ខណៈដែលឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រមាណជិតពាក់កណ្តាល មានរយៈពេលច្រើនជាង ៣ឆ្នាំ ។ ឥណទានរបស់គ្រឹះស្ថានធនាគារមានទំហំធំ ដែលមានចាប់ពី ៥០០.០០០ ដុល្លារអាមេរិក រហូតដល់ច្រើនជាង ១០.០០០.០០០ ដុល្លារអាមេរិក ខណៈដែលឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានទំហំតូចជាង៥០០.០០០ ដុល្លារអាមេរិក ។ ក្នុងនោះ ឥណទានរបស់គ្រឹះស្ថានធនាគារប្រមាណ ៣១% មានទំហំច្រើនជាង ១០.០០០.០០០ ដុល្លារអាមេរិក និង ប្រមាណ ៦២% នៅចន្លោះពី ១.០០០.០០០ ដុល្លារអាមេរិក ទៅ១០.០០០.០០០ ដុល្លារអាមេរិក ចំណែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ ឥណទានភាគច្រើនគឺមានទំហំពី ៥.០០០ ដុល្លារអាមេរិក ទៅ ១០០.០០០ ដុល្លារអាមេរិក ហើយទន្ទឹមនេះ មានឥណទានប្រមាណ ៦% ដែលមានទំហំច្រើនជាង ១០០.០០០ ដុល្លារអាមេរិក និង ប្រមាណ ២០% ដែលមានទំហំតិចជាង ៥.០០០ ដុល្លារអាមេរិក ។

ក្នុងការសងត្រលប់មកវិញ មានវិធីសាស្ត្រចំនួន ២ ដែលអតិថិជនចូលចិត្តប្រើប្រាស់ គឺ វិធីសាស្ត្របង់រំលោះ (Installment) និង វិធីសាស្ត្របង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា (Balloon) ។ ករណីនេះមានភាពខុសគ្នារវាងគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយអតិថិជនរបស់គ្រឹះស្ថានធនាគារភាគច្រើនជ្រើសរើសវិធីសាស្ត្របង់រំលោះក្នុងការសងបំណុលជាងវិធីសាស្ត្របង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា ខណៈដែលអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិយមការសងបំណុលតាមវិធីសាស្ត្របង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា ជាងវិធីសាស្ត្របង់រំលោះ ។ ទន្ទឹមនេះ មានអតិថិជនមួយចំនួនបានជ្រើសរើសវិធីសាស្ត្របង់តាមរដូវកាល (Seasonal Repayment) ផងដែរ ។ ឥណទានមិនដំណើរការចំពោះវិស័យកសិកម្មហាក់មានកម្រិតទាប ដោយអត្រានៃការខាតបង់របស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុប្រមាណ ៧០% គឺតិចជាង ០,៥% ហើយគ្រឹះស្ថានភាគច្រើនបានបង្ហាញថា ប្រសិនបើគ្រឹះស្ថានពិនិត្យឃើញថាវិស័យកសិកម្ម ជាពិសេសវិស័យស្រូវ-អង្ករមានការរីកចម្រើនជាលំដាប់ នោះគ្រឹះស្ថាននឹងយកចិត្តទុកដាក់បន្ថែមក្នុងការពង្រីកឥណទានដល់វិស័យនេះ ។

## ៤. ការសន្និដ្ឋាននិងផ្តល់យោបល់លើការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម

ទន្ទឹមនឹងការរីកចម្រើននៃវិស័យកសិកម្ម ក៏ដូចជាការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលលើវិស័យកសិកម្ម វិស័យនេះមានការរីកចម្រើនជាលំដាប់ ដែលឆ្លុះបញ្ចាំងដោយកំណើននៃការនាំចេញអង្ករ ។ ប៉ុន្តែ បើទោះជាការនាំចេញមានកំណើនជាលំដាប់ក៏ដោយការសិក្សាបានបង្ហាញថា វិស័យស្រូវ-អង្ករប្រឈមនិងបញ្ហាមួយចំនួន ដូចជា ៖ ប្រជាកសិករមិនអាចទទួលបានទិន្នផលពីការដាំដំណាំស្រូវតាមការរំពឹងទុក ដោយសារពឹងផ្អែកច្រើនលើអាកាសធាតុ ហើយកសិករនិងរោងម៉ាស៊ីនកិនស្រូវប្រឈមនឹងការរកទីផ្សារ និងការចំណាយថ្លៃដើមខ្ពស់ក្នុងការផលិតស្រូវ-អង្ករ ។ ទន្ទឹមនេះ បើទោះជារោងម៉ាស៊ីនកិនស្រូវប្រមាណ ៣៥% បានលើកឡើងថាការខ្វះខាតធនធានហិរញ្ញវត្ថុជាបញ្ហាប្រឈមចម្បង ប៉ុន្តែមានប្រជាកសិករមួយចំនួនតូចប៉ុណ្ណោះដែលបានលើកឡើងអំពីបញ្ហានេះ ហើយការលំបាកក្នុងការទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺដោយសារការខ្វះខាតវត្ថុបញ្ចាំនិងអត្រាការប្រាក់ខ្ពស់ ។ គួរបញ្ជាក់ផងដែរថា ការយល់ដឹងអំពីតម្រូវការជាក់ស្តែងនិងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ គឺមានសារៈសំខាន់ណាស់សម្រាប់ធានាបាននូវភាពជោគជ័យរបស់អាជីវកម្ម ហើយការប្រើប្រាស់ធនធានហិរញ្ញវត្ថុឲ្យចំគោលដៅនិងត្រឹមត្រូវ រឹតតែសំខាន់ថែមទៀតដើម្បីបង្ការការខាតបង់ធ្ងន់ធ្ងរដល់អាជីវកម្ម ។ ចំពោះការផ្តល់ហិរញ្ញប្បទាន គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ក្នុងនោះឥណទានប្រមាណ ១៥,៥% នៃបរិមាណឥណទានសរុបរបស់គ្រឹះស្ថាន ត្រូវបានផ្តល់ដល់វិស័យកសិកម្ម ។

យោងតាមលទ្ធផលនៃកាសិក្សាស្រាវជ្រាវ ដើម្បីបង្កើនហិរញ្ញប្បទានវិស័យកសិកម្ម គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចនឹងពិចារណាលើវិធានមួយចំនួនដូចខាងក្រោម ៖

- ក្នុងការផ្តល់ឥណទានដល់អតិថិជន គ្រឹះស្ថានអាចពិចារណាលើលទ្ធភាពនៃការសង ជាជាងវត្ថុបញ្ចាំ ដូចជា ការប្រើប្រាស់ទិន្នន័យឥណទានរបស់ការិយាល័យឥណទាន ក្នុងការវិភាគនិងវាយតម្លៃគុណភាពអតិថិជន ដែលអាចជំរុញឲ្យអតិថិជនដែលពុំមានទ្រព្យបញ្ចាំអាចមានលទ្ធភាពទទួលបានហិរញ្ញប្បទានដើម្បីបង្កើនជីវភាពរស់នៅ ក៏ដូចជាការបង្កើនឱកាសដល់គ្រឹះស្ថានក្នុងការពង្រីកចំណែកទីផ្សារឥណទានដែលមានភាពរឹងមាំ
- ការទទួលយកតែអចលនទ្រព្យ (លំនៅដ្ឋាន ដីធ្លី និង អគារ ជាដើម) ជាទ្រព្យបញ្ចាំ បានបង្កឲ្យអតិថិជនដែលមិនមានអចលនទ្រព្យ តែមានចលនទ្រព្យ មិនអាចមានលទ្ធភាពទទួលបានឥណទានពីគ្រឹះស្ថាន ។ គ្រឹះស្ថានគួរពិចារណាលើចលនទ្រព្យផ្សេងទៀតក្រៅពីអចលនទ្រព្យ ដូចជា ៖
  - ការផ្តល់ហិរញ្ញប្បទានសារពើភ័ណ្ឌ (Inventory Financing) គឺជាប្រភេទមួយនៃការផ្តល់ឥណទានឬប្រាក់កម្ចីរយៈពេលខ្លី ដោយទទួលយកសារពើភ័ណ្ឌជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចី ប្រសិនបើអ្នកខ្ចីប្រាក់មិនមានលទ្ធភាពសង
  - ការផ្តល់ហិរញ្ញប្បទានតាមបញ្ចាំស្តុក (Warehouse Receipt Financing) គឺជាទម្រង់មួយនៃការផ្តល់ហិរញ្ញប្បទានសារពើភ័ណ្ឌ ដោយអតិថិជនប្រើប្រាស់វិក័យប័ត្របញ្ជាក់ពីទំនិញដែលខ្លួនមាននៅក្នុងឃ្លាំងស្តុក ជាវត្ថុបញ្ចាំសម្រាប់ធានាលើប្រាក់កម្ចីរបស់ខ្លួន ហើយឃ្លាំងស្តុកទំនិញ

នេះអាចជាឃ្លាំងសាធារណៈ ដែលបានទទួលស្គាល់ដោយអ្នកផ្តល់ប្រាក់កម្ចី ឬ ជាឃ្លាំងដែលស្ថិតនៅក្នុងទីតាំងរបស់អ្នកខ្ចី គ្រប់គ្រងដោយភាគីឯករាជ្យទីបី ។

- ការបង្កើនការយល់ដឹងរបស់កសិករ សមាគមកសិករ និងរោងម៉ាស៊ីនកិនស្រូវ អំពីផលិតផលនិងសេវាហិរញ្ញវត្ថុ ក៏ដូចជាការប្រើប្រាស់ធនធានហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ ដើម្បីជំរុញឲ្យការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ឲ្យមានប្រសិទ្ធភាពនិងចំគោលដៅ
- ការបណ្តុះបណ្តាលជាមូលដ្ឋានដល់កសិករ សមាគមកសិករ និងរោងម៉ាស៊ីនកិនស្រូវ អំពីការរៀបចំផែនការអាជីវកម្ម ការកត់ត្រា និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្កើនជំនឿទុកចិត្តពីគ្រឹះស្ថានផ្តល់ហិរញ្ញប្បទាន
- ការខិតខំស្វែងយល់បន្ថែមរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អំពីដំណើរការនិងផលិតផលស្រូវ-អង្ករ ដើម្បីពង្រឹងគុណភាពនៃការផ្តល់ឥណទានលើវិស័យនេះ
- ការបង្កើនផ្តល់ប្រាក់កម្ចីជាប្រាក់រៀល ដែលអាចសម្រួលដល់ប្រតិបត្តិការទិញសម្ភារៈកសិកម្មនិងវត្ថុធាតុដើមរបស់កសិករ ដោយសារប្រតិបត្តិការភាគច្រើនទូទាត់ជាប្រាក់រៀល ។

ជាមួយគ្នាផងដែរ ការចូលរួមពីស្ថាប័ននិងភាគីពាក់ព័ន្ធផ្សេងទៀត ក៏អាចនឹងបង្កើនលទ្ធភាពដល់កសិករក្នុងការទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ផងដែរ ដូចជា ៖

- ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធធារាសាស្ត្រ និង ផ្លូវថ្នល់ ជាដើម ដើម្បីសម្រួលដល់ការដាំដុះនិងដឹកជញ្ជូនដំណាំស្រូវ ដែលជាកត្តាសំខាន់ក្នុងការបង្កើនផលនិងការកាត់បន្ថយថ្លៃដើមផលិត
- ការធានាបាននូវទីផ្សារនិងតម្លៃស្រូវដែលអាចទទួលយកបាន ចំពោះផលិតផលស្រូវដែលកសិករប្រមូលបាន ព្រមទាំងការពង្រីកទីផ្សារសម្រាប់នាំចេញអង្ករ
- ការផ្តល់សិទ្ធិកាន់កាប់លើអចលនទ្រព្យតាមរយៈការចុះបញ្ជីដីធ្លីរបស់ប្រជាជន ជាពិសេសនៅតំបន់ជនបទ ដែលជំរុញឲ្យកសិករងាយស្រួលប្រើប្រាស់បណ្ណ័កម្មសិទ្ធិអចលនទ្រព្យ សម្រាប់ជាវត្ថុបញ្ចាំក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

# ឯកសារយោង


១- វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០១៥

២- ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៥ "របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ" ភ្នំពេញ

៣- លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ "របាយការណ៍ស្ថានភាពនៃការនាំចេញអង្ករឆ្នាំ២០១៥" ភ្នំពេញ

៤- ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank – ADB) http://www.adb.org/countries/cambodia/economy (០២/០៨/២០១៦)

៥- រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០ "គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ" ភ្នំពេញ

៦- រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣ "យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធិភាព នៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ភ្នំពេញ

៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ២០១១ "ផែនការសកម្មភាពសម្រាប់អនុវត្ត ឯកសារគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ" ភ្នំពេញ

៨- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ២០១៣ "សមិទ្ធផលសំខាន់ៗរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទសម្រាប់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ចីរភាព ការអភិវឌ្ឍន " ភ្នំពេញ

៩- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០១៥ "អង្ករកម្ពុជា" សក្តានុពលនិងយុទ្ធសាស្ត្រនាំចេញ កសិអាជីវកម្ម កម្ពុជា លេខ ៤

១០- អង្គការម្ហូបអាហារនិងកសិកម្ម ឆ្នាំ២០១៤ "FAOStat Online Database" http://faostat.fao.org (២៣/០៩/២០១៤)

១១- ធនាគារពិភពលោក ឆ្នាំ២០១៣ "ការសិក្សាអំពីការទទួលបានសេវាហិរញ្ញវត្ថុរបស់សហគ្រាសកសិអាជីវកម្ម ខ្នាតតូច និងមធ្យមនៅកម្ពុជា" ឯកសារស្រាវជ្រាវបច្ចេកទេស របស់ ការិយាល័យអភិវឌ្ឍន៍ជនបទ ធនធានធម្មជាតិ និង វិស័យបរិស្ថាន នៅតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិក